ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

កំណត់ហេតុកិច្ចប្រជុំថ្នាក់ដឹកនាំ
អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែវិច្ឆិកា ឆ្នាំ២០២២

១. សេចក្តីផ្តើម

នៅថ្ងៃសុក្រ ៩កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ ចាប់ពីម៉ោង ៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តមអនុប្រធានប្រចាំការ ឯកឧត្តមអនុប្រធាន ឯកឧត្តមទីប្រឹក្សា នាយកខុទ្ទកាល័យ ឯកឧត្តមអគ្គលេខាធិការ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានទាំងបួន។

កិច្ចប្រជុំដំណើរការតាមរបៀបវារៈដូចខាងក្រោម ៖

១) មតិស្វាគមន៍ និងបើកកម្មវិធីរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២) បទបង្ហាញរបាយការណ៍ថ្នាក់ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉ែត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣) បទបង្ហាញរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផល** ស្តីពីដំណោះស្រាយបញ្ហាក្នុងការសម្របសម្រួលនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

៤) ការផ្តល់មតិយោបល់របស់ថ្នាក់ដឹកនាំ។

២. ដំណើរការ និងមតិពិភាក្សានៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី បានបើកកិច្ចប្រជុំ និងមានមតិស្វាគមន៍ដល់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំប្រចាំខែ ដោយផ្ទាល់ និងតាមប្រព័ន្ធនិមិត្ត

ដែលជាឱកាសមួយក្នុងការពិនិត្យលើការងាររបស់អាជ្ញាធរជាតិយើង ព្រោះក្នុងខែវិច្ឆិកានេះយើងមានព្រឹត្តិការណ៍សំខាន់ៗច្រើន។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់ថា យើងអាចចាត់ទុកថា ជាជោគជ័យមួយចំនួនថែមទៀតរបស់យើង ដោយមានការចូលរួម និងមានការចាប់អារម្មណ៍ច្រើនពីថ្នាក់ដឹកនាំគ្រប់ស្ថាប័នក្នុងការចូលរួមជាមួយយើង។

ក) របាយការណ៍សកម្មភាពដោយ ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉ែត អគ្គលេខាធិការ៖

សេចក្តីរាយការណ៍ពីសកម្មភាព លទ្ធផលនានារបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ។

នៅក្នុងបទបង្ហាញរបាយការណ៍ថ្នាក់ដឹកនាំ បានឆ្លុះបញ្ចាំងពីសកម្មភាពក្នុងការរៀបចំព្រឹត្តិការណ៍ធំៗជាច្រើន។ របាយការណ៍បានគូសបញ្ជាក់ពីសកម្មភាពដ៏មមាញឹករបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមអនុប្រធានប្រចាំការ ឯកឧត្តមអនុប្រធាន ក៏ដូចជាសកម្មភាព និងលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ។ សកម្មភាព និងព្រឹត្តិការណ៍សំខាន់ៗរួមមាន៖

- ការរៀបចំផែនទីបង្ហាញផ្លូវ ស្តីពីនិរន្តរភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍
- កិច្ចប្រជុំពេញអង្គលើកទី២ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- សន្និបាតប្រចាំឆ្នាំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២២
- ជំនួបពិភាក្សាការងាររវាងឯកឧត្តមទេសរដ្ឋមន្ត្រី និងគណៈប្រតិភូ ជាមួយអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ស្តីពីស្ថានភាព និងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។
- ការផ្តល់បទសំភាសន៍ជាមួយទូរទស្សន៍បាយ័ន ក្នុងការផ្សព្វផ្សាយសាររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ដែលបានផ្សាយតាមបណ្តាញទូរទស្សន៍ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២២។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់ថា ក្នុងរយៈពេលជិតមួយឆ្នាំ២០២២នេះ យើងអាចបូកសរុបបានថា យើងបានបំពេញការងារបានច្រើនគួរជាទីមោទនៈ ជាពិសេសក្រោយពេលសភាពការឆ្លងរាលដាលជំងឺកូវីដបានធូរស្រាល និងអាចបើកប្រទេសឡើងវិញ។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានបន្ថែមទៀតថា យើងហៀបតែនឹងបានជោគជ័យធំក្នុងការចូលជាសមាជិកភាពនៃក្រុមប្រឹក្សាសម្របសម្រួលកម្មវិធី (PCB) អង្គការ UNAIDS ទៅហើយ តែដោយសារមានការផ្តល់ព័ត៌មានមកយើងមានការយឺតយ៉ាវពេក ហើយការដាក់បេក្ខភាពរបស់យើងក៏មិនទាន់ពេលក្នុងឆ្នាំនេះ តែយើងមានសង្ឃឹមនៅឆ្នាំក្រោយទៀត។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានផ្តល់អនុសាសន៍ដល់ **ឯកឧត្តម ទា ផល** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវទាក់ទងជាមួយនឹង UNAIDS ឱ្យបានមុនប្រសិនបើ

UNAIDS ប្រាប់ទៅប្រទេសណាមួយជាប្រធានក្រុមនៃប្រទេសតំបន់អាស៊ីប៉ាស៊ីហ្វិក អំពីសមាជិកភាពនៃក្រុមប្រឹក្សាសម្របសម្រួលកម្មវិធី (PCB) របស់ UNAIDS សូម UNAIDS ឱ្យដំណឹងផ្ទាល់មកអាជ្ញាធរយើងផង ។

ក្រៅពីនេះ នៅមានការងារមួយចំនួនទៀតដែលត្រូវបំពេញដូចជា៖

- ការកែសម្រួលសេចក្តីសម្រេចក្នុងការបង្កើតក្រុមការងារបញ្ចប់អេដស៍នៅឆ្នាំ២០២៥ និងត្រូវមានកិច្ចប្រជុំនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២នេះ។
- ការរៀបចំអនុក្រឹត្យរបស់យើង ពេលនេះបានដល់ក្រុមប្រឹក្សាអ្នកច្បាប់រួចរាល់ហើយ យើងនៅរង់ចាំការសម្រេចដ៏ខ្ពង់ខ្ពស់ពីសម្តេចតេជោនាយករដ្ឋមន្ត្រី ហើយនេះក៏ជាជោគជ័យមួយយ៉ាងធំ។
- ឯកឧត្តមទេសរដ្ឋមន្ត្រីនឹងចូលរួមជាអធិបតីក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ព្រោះត្រូវការស្វែងយល់បន្ថែមពីបញ្ហាទាក់ទងនឹងស្ត្រីបំរើសេវាកម្សាន្តសប្បាយ EWs ជាពិសេសក្នុងការផ្តល់ប័ណ្ណសមធម៌ដល់ពួកគេ។ វាក៏ជាឱកាសល្អក្នុងការជំរុញឱ្យពួកគាត់មកធ្វើតេស្តឈាមរកមេរោគអេដស៍ផងដែរ។ ការផ្តល់កិច្ចសន្យាការងារដល់ EWs ជាពិសេសក្រុមស្ត្រីឯករាជ្យក៏ត្រូវតែមានការសិក្សាបន្ថែមជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- សិក្សាបន្ថែមក្នុងការជំរុញឱ្យក្រុមប្រជាជនគន្លឹះ មកធ្វើតេស្តឈាម ត្រូវតែមានការលើកទឹកចិត្តដូចជាការផ្តល់ប័ណ្ណសមធ៌ម (ID poor) ជាដើម។

ខ) បទបង្ហាញដោយឯកឧត្តមបណ្ឌិត ទា ផល អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តម ទា ផល អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានធ្វើបទបង្ហាញពីបំរែបំរួលនៃតួនាទីសម្របសម្រួលរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពីកម្រិត១ ទៅកម្រិត១ទៀត ជាបន្តបន្ទាប់ៈ ស្ថានភាពនៃការឆ្លើយតបមេរោគអេដស៍របស់យើងគឺ គោលដៅ ៩៥ទី១ យើងទទួលបានចំណាត់ថ្នាក់លេខ២ ចំណែកឯគោលដៅ ៩៥ទី២ យើងបានចំណាត់ថ្នាក់លេខ១។ បើពិនិត្យមើលលើអត្រាចម្លងមេរោគថ្មី យើងបានចំណាត់ថ្នាក់លេខ៨ នៅក្នុងតំបន់អាស៊ីបាស៊ីហ្វិក។

- អត្រាឆ្លងមេរោគអេដស៍មានការកើនឡើងក្នុងចំណោមក្រុម MSM&TG រីឯការវិនិយោគ និងបទអន្តរាគមន៍នៅមិនទាន់សមស្របនៅឡើយ។ ជាទូទៅមានការទទួលស្គាល់ថាអត្រាមេរោគអេដស៍ថ្មី (New infection) មានការថយចុះ។
- តួនាទីរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍គឺជាអ្នកដឹកនាំសម្របសម្រួល ចលនាធនធាន ត្រួតពិនិត្យ និងវាយតម្លៃ ក្នុងគោលដៅបញ្ចប់អេដស៍នៅឆ្នាំ២០២៥។

- ប្រសិនបើយើងយករបៀបធ្វើការបែប Problem Driven Interactive Adaptation (PDIA) មកសិក្សា គឺមាន២ ការបញ្ចប់អេដស៍ និងនិរន្តរភាពនៃការឆ្លើយតបមេរោគអេដស៍ (Ending AIDS and Sustainability HIV Response)។
- តួនាទីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍គឺធំ តែក្នុងការអនុវត្តជាក់ស្តែងអាជ្ញាធរជាតិបានទទួលថវិកាតូចមែនទែន ដែលមិនសក្តិសមនឹងតួនាទីក្នុងការដឹកនាំ សម្របសម្រួលទូទាំងប្រទេស។
- បញ្ហាដែលមាននៅក្នុងរបាយការណ៍វាយតម្លៃក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ (MTR-NSP) ដែលមាន២៨ ចំណុចត្រូវតែដោះស្រាយតាមរយៈក្រុមការងារយុទ្ធសាស្ត្រជាតិ។
- ផែនទីបង្ហាញផ្លូវ ស្តីពីនិរន្តរភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ មាន១០ ចំណុចត្រូវការអន្តរក្រសួងដោះស្រាយ ត្រូវដឹកនាំដោយរដ្ឋាភិបាល (Policy Ending AIDS, Sustainability Response, Fiscal Space) និងត្រូវគោរពគោលការណ៍ បី-មួយ (Three-One Principle)។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវអភិវឌ្ឍន៍ខ្លួនជាអ្នកអនុវត្ត ត្រួតពិនិត្យ NSP V ទាំង ២៨ចំណុច និង១០ចំណុចរបស់ SRM និងត្រូវអភិវឌ្ឍន៍ការអនុវត្តទៅតាមតួនាទីដែលបានចែង។
- ក្រុមការងារយុទ្ធសាស្ត្រទាំង៥ (NSP Strategy TWG) របស់យើងត្រូវតែដំណើរការ។

ឃ) អនុសាសន៍ របស់ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ថា បទបង្ហាញរបស់ឯកឧត្តម ទា ផលា បានផ្តល់ជាតុចូលបន្ថែមច្រើនទៀតក្នុងការជំរុញការអនុវត្តការងារ។ លោកក៏បានបញ្ជាក់ថា ការងាររបស់យើងគឺមិនមែនតែជាអ្នកអនុវត្តគម្រោងមូលនិធិសកលនេះទេ តែយើងជាអ្នកដឹកនាំ សម្របសម្រួលក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ដូច្នេះយើងត្រូវតែទុកតួនាទីធំរបស់យើងជាការសំខាន់ និងមានការប្តេជ្ញាចិត្តខ្ពស់ស្របទៅតាមច្បាប់ព្រះរាជក្រឹត្យ លិខិតណែនាំផ្សេង ដូចជា ស.ជ.ណ ២១៣ ជាដើម ។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានបន្ថែមថា រាល់កិច្ចប្រជុំយើងមិនត្រូវដាក់តែបញ្ហាទេ គឺត្រូវរកដំណោះស្រាយផង។ ការងារដែលត្រូវធ្វើគឺការបញ្ចប់អេដស៍នៅឆ្នាំ២០២៥ ព្រោះបើយើងនៅតែមិនទាន់បានសម្រេចបានគោលដៅ ៩៥ទី១ ប៉ុណ្ណោះ ចំណែកឯគោលដៅ៩៥ទី២ គឺបានរហូតដល់ ៩៩,៩% ក្រៅពីនេះត្រូវធ្វើយ៉ាងណាឱ្យការឆ្លងថ្មីមកត្រឹម ៥០០ ទៅ៦០០នាក់/១ឆ្នាំ។ ចំពោះការងារបន្ត គឺជំរុញការងារ PrEP ឱ្យបានដល់ ១០០០០នាក់ ទៅ៥០០០០នាក់/១ឆ្នាំ។ ចំពោះការងារសម្របសម្រួលមូលនិធិសកលវិញគឺខាងមូលនិធិសកលបានគាំទ្រដល់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវមានតួនាទីដឹកនាំសម្របសម្រួល Country Dialogue ហើយសម្រាប់អាណត្តិក្រោយ អាជ្ញាធរជាតិយើងនឹងទទួលយកតួនាទីនេះក្នុងការសម្របសម្រួល Country Dialogue ដែលមានតួនាទីដឹកនាំក្នុងការបែងចែកថវិកាផងដែរ ។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ពីការងារផ្សេងៗទៀតដែលត្រូវធ្វើ៖

- ត្រូវបន្តរៀបចំផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ (NSP-VI) ដោយត្រូវមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចទៅដល់ការងារបន្តរកអ្នកបាត់ជាង ១០០០០នាក់ និងកម្មវិធីបង្ការទាក់ទងនឹងគោលដៅ ៩៥ទី១ ដោយមានការជំរុញការធ្វើតេស្តឈាម ការប្រើប្រាស់ស្រោមអនាម័យ ការអប់រំបង្ការមេរោគអេដស៍ក្នុងចំណោមយុវវ័យ ការលើកទឹកចិត្តក្រុមប្រជាជនគន្លឹះឱ្យមកធ្វើតេស្តឈាមរកមេរោគអេដស៍ជាដើម។ ក្រៅពីនេះត្រូវតែមានការដោះស្រាយបញ្ហាហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធិភាព ការសម្របសម្រួលតួនាទីយើងកាន់តែធំ និងការពង្រឹងសមត្ថភាពបន្ថែមជាប់ជានិច្ច។
- ចំពោះការរៀបចំគោលនយោបាយជាតិបញ្ចប់អេដស៍ ឆ្នាំ២០២៥ ត្រូវមាន២ក្រុមគឺ ក្រុមទី១) ក្រុមស្នូល ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ហោ ប៊ុនឡេង** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រុមទី២) ក្រុមអន្តរក្រសួងដឹកនាំដោយ **ឯកឧត្តមវេជ្ជ ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទទួលបន្ទុកបច្ចេកទេស។
- ឯកឧត្តមអគ្គលេខាធិការត្រូវធ្វើការជាមួយបណ្តារាជធានី ខេត្ត ដោយយកតួរលេខពិតប្រាកដទូទាំងប្រទេស ទាក់ទងនារីបម្រើសេវានៅតាមសួនច្បារ ជាប្រជាជនចល័តដោយចាប់ផ្តើមពី រាជធានីភ្នំពេញ ហើយត្រូវរកចំនួនអ្នកបំរើការផ្លូវភេទក្រីក្រ ដើម្បីសុំគោលការណ៍ផ្តល់បំណ្ណសមធម៌ដល់ពួកគាត់ជាជំហានៗ។

អង្គប្រជុំ បានបញ្ចប់នៅវេលាម៉ោង ១១ និង០៨ នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល។

ថ្ងៃចន្ទ ១២កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ត្រូវនឹងថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២

អ្នកធ្វើកំណត់ហេតុ

វេជ្ជ. ទេព ណារុង

បានពិនិត្យត្រឹមត្រូវ
អគ្គលេខាធិការ អ.ជ.ប.ជ.អ

បណ្ឌិត ឈឹម យិនដារ៉ែត

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ
ទេសរដ្ឋមន្ត្រីប្រធាន អ.ជ.ប.ជ.អ

អៀង_អូលី